ក្រុមការងារយេនឌ័រ

# បទបង្ហាញក្រុមការងារយេនឌ័រ
# ក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២២

# សេចក្តីផ្តើម

ក្រុមការងារយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំអនុវត្តន៍ផែនការយុទ្ធសាស្រ្តបញ្ជ្រាប យេនឌ័រ ២០១៩-២០២៣ ឲ្យស្របទៅតាមអាណត្តិរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅចូលរួមចំណែកលុបបំបាត់វិសមភាពយេនឌ័រក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងសំដៅចូលរួមលើកកម្ពស់សិទ្ធិមនុស្ស និងកាត់បន្ថយភាពក្រីក្រ ជាពិសេសដើម្បីលើកកម្ពស់ជីវភាពស្រ្តី និងគ្រួសារពួកគាត់ឲ្យបានល្អប្រសើរ ។ តាមរយៈក្រុមការងារយេនឌ័រក្រសួងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្សព្វផ្សាយអំពីទស្សនៈ  យេនឌ័រ អនុសញ្ញា ស៊ី-ដ ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្រ្តី ទប់ស្កាត់អំពើហឹង្សាលើស្រ្តី។

# I. សមិទ្ធផលសម្រេចបាន

## ១. ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

ក្រុមការងារយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទ បានធ្វើការផ្សព្វផ្សាយស្តីពី ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ អនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងអនុសាសន៍របស់ សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងការបណ្តុះបណ្តាលអំពីចំណេះដឹងយេនឌ័រ និងការបង្កើនភាពអង់អាចសេដ្ឋកិច្ចដល់ស្ត្រីនៅតាម សហគមន៍ ដល់បណ្តាញការងារយេនឌ័រនៅតាមមន្ទីររាជធានី ខេត្ត និងទៅដល់ប្រជាជន និងអាជ្ញាធរមូលដ្ឋាន ។ជាក់ស្តែងក្រុមការយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទ បានចុះផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងបណ្តុះបណ្តាលស្តីពីទស្សនៈយេនឌ័រ និងអនុសញ្ញា CEDAW ពិធីសារតាមជម្រើសនិងច្បាប់ពាក់ព័ន្ធនានាអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប។

ក្នុងឆ្នាំ២០២២ នេះដោយមានការយកចិត្តទុកដាក់ពី **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** យើងបានរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ដែលដឹកនាំដោយ**លោកជំទាវ ម៉ាត់ ម៉ារ៉ា** បានចុះជួបសំណេះសំណាល សួរសុខទុក្ខ បងប្អូនមន្ត្រីរាជាការជាស្ត្រីតាមនាយកដ្ឋាន និមួយៗប្រកបដោយភាពស្និទ្ធស្នាល និងបាននាំយកនូវថវិការបស់ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី លើកទឹកចិត្តដល់មន្ត្រីរាជការជាស្ត្រី នូវថវិកាម្នាក់ ២០ ម៉ឺនរៀល ។

## II. បញ្ហាប្រឈម

នាពេលកន្លងមកនេះ ក៏ដូចជាសមិទ្ធផលសម្រេចបាន ឆ្នាំ២០២២ របស់ក្រុមការយេនឌ័រ ទទួលបានជោគជ័យ ក្នុងការទទួលបានថវិកាជាតិ ដើម្បីអនុវត្តការងារបញ្ជ្រាបយេនឌ័ររបស់ខ្លួនមែន ប៉ុន្តែថវិកានេះនៅមានកម្រិតនៅឡើយ មិនទាន់សមស្របទៅនឹងតម្រូវការជាក់ស្តែងក្នុងការបង្កើនសមភាពយេនឌ័រនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ ជាពិសេសក្នុងបរិបទនៃការរាតត្បាត នៃជំងឺកូវីដ-១៩ ដែលត្រូវកាត់បន្ថយថវិកាបណ្តាលជះឥទ្ធិពលលើសកម្មភាពការងារ ។ ម្យ៉ាងវិញទៀតបើទោះបីជា មានការគាំទ្រពីថ្នាក់ដឹកនាំក្រសួងតែគម្រោងខ្លះមិនទាន់មានភាពរលូនក្នុងកិច្ចសហការ ដែលក្រុមការងារយេនឌ័រមិនសូវទទួលបានព័ត៌មានថាតើគម្រោងបានបន្សុំផែនការសកម្មភាពរបស់ខ្លួនជាមួយ នឹងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងបានកម្រិតណា ។ សម្ថភាពក្រុមការងារយេនឌ័រនៅមានកម្រិត លើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីដឹងថាតើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ មានភាពរីកចម្រើនសមស្របទៅតាមផែនការគ្រោងទុក ។

## III. មេរៀន និងបទពិសោធ

### + ចំណុចខ្លាំង

- ការលើកកម្ពស់សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រីលើគ្រប់វិស័យ និងគ្រប់កម្រិត គឺជារបៀបវារៈអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា

- កិច្ចសហការ ភាពជាដៃគូ និងការគាំទ្រពីក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បានរួមចំណែកក្នុងការធ្វើឲ្យមានសមភាពយេនឌ័រ

-ស្ត្រីមានការកើនឡើងជាបន្តបន្ទាប់ក្នុការធ្វើសេក្តីសម្រេចចិត្ត

+ **ចំណុចខ្សោយ**

- ថវិកាសម្រាប់អនុវត្តការបញ្ជ្រាបយេនឌ័រនៅមានកម្រិត

- សមត្ថភាពក្រុមការងារយេនឌ័រនៅមានកម្រិត លើកការងារតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

- ស្ត្រីមិនទាន់បានទទួលបានក្នុងការធ្វើសេចក្ដីសម្រេចចិត្តនៅកន្លែងមួយចំនួនតូចដែលអវត្តមានចំនួនស្ត្រីជាយូរហើយ ។

- សមាជិកក្រុមការងារយេនឌ័រ ជាប់រវល់ការងារជំនាញ មិនមានពេលគ្រប់គ្រាន់ចូលរួមតាមការចាត់តាំង

# សំណូមពរ

- កិច្ចសហការរវាងក្រុមការងារយេនឌ័រជាមួយគ្រប់គម្រោងផ្សេងៗ ដើម្បីជួយជំរុញការបញ្ជ្រាបយេនឌ័រគ្រប់លំដាប់ថ្នាក់ និងបន្តការផ្សព្វផ្សាយ ដល់សហគមន៍បន្ថែមទៀត

- បង្កើនថវិកាសម្រាប់អនុវត្តការបញ្ជ្រាបយេនឌ័រ ដើម្បីឆ្លើយតមទៅនឹងការអនុវត្តផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រ ។